មជ្ឈមណ្ឌលឯកសារកម្ពុជា

# ការអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា

## វគ្គបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋានលើកទី១៧
## ស្តីពីការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩)
## នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ កំពង់ចាម
## ថ្ងៃទី៣ ដល់ ថ្ងៃទី៧ ខែមេសា ឆ្នាំ២០១៧

*"នេះគឺជាគម្រោងសំណងតាមផ្លូវតុលាការរបស់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ដែលត្រូវបាន ស្នើឡើងដើម្បីប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះក្នុងសំណុំរឿង០០២/០១"*

## សេចក្តីប្រកាសព័ត៌មាន

មជ្ឈមណ្ឌលឯកសារកម្ពុជា/វិទ្យាស្ថានស្លឹករឹត និងក្រសួងអប់រំ យុវជន និងកីឡា ក្រោមជំនួយទ្រទ្រង់ទាំងស្រុងពីសហគមន៍អឺរ៉ុប និងការគាំទ្រចម្បងពីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ មានកិត្តិយសសូមប្រកាសបើកវគ្គបណ្តុះបណ្តាលគ្រូបង្រៀនលើកទី១៧ នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ កំពង់ចាម ចាប់ពីថ្ងៃទី៣ ដល់ថ្ងៃទី៧ ខែមេសា ឆ្នាំ២០១៧។ វគ្គបណ្តុះបណ្តាល នេះមានរយៈពេល៥ថ្ងៃ និងមានសិក្ខាកាមចូលរួមប្រមាណ១២០រូប។

មជ្ឈមណ្ឌលឯកសារកម្ពុជា បាននិងកំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយមន្ទីរអប់រំ យុវជន និងកីឡា ក្នុងខេត្តចំនួន៦គឺ ខេត្តកំពង់ចាម ត្បូងឃ្មុំ ក្រចេះ ស្ទឹងត្រែង រតនៈគិរី និងមណ្ឌលគិរី ដើម្បីធានាថា ចំនួនសិក្ខាកាមភាគច្រើនដែលមកពីបណ្តាខេត្តទាំងនេះ បានចូលរួមគ្រប់គ្នា។ វគ្គបណ្តុះបណ្តាលនេះ នឹងផ្តល់ដល់សិក្ខាកាមទាំងអស់នូវព័ត៌មាន និងចំណេះដឹងពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ក៏ដូចជាវិធីសាស្ត្របង្រៀនគោលវិធីសិស្សមជ្ឈមណ្ឌលដ៏សម្បូរណ៍បែប ដែលត្រូវបានរៀបចំឡើងដើម្បីឆ្ពោះទៅរកការពង្រឹងសមត្ថភាពគ្រូបង្រៀនម្នាក់ៗ ជំនាញក្នុងការបង្រៀន និងកម្មវិធីសិក្សាសម្រាប់សាលារៀននៅកម្ពុជា។ តាមរយៈវគ្គបណ្តុះបណ្តាលនេះ សិក្ខាកាមម្នាក់ៗនឹងក្លាយជាអ្នកអប់រំដែលមានចំណេះដឹងជ្រៅជ្រះ និងមានប្រសិទ្ធិភាព ដែលអាចដឹកនាំសិស្សានុសិស្សឲ្យសិក្សាពីប្រវត្តិសាស្ត្រខ្លួនឯង និងពិភាក្សារឿងរ៉ាវក្នុងអតីតកាលជាមួយអ្នករស់រានមានជីវិតដែលមានទីលំនៅក្នុងសហគមន៍ជាមួយគ្នា។ លើសពីនេះទៀត សិក្ខាកាមទាំងអស់ នឹងមានឱកាសជួបជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលបច្ចុប្បន្នជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម។

រហូតមកដល់ពេលបច្ចុប្បន្ន ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩) នៅតែផ្តល់ផលប៉ះពាល់ដល់ប្រទេសកម្ពុជា។ ប្រជាជនកម្ពុជារាប់លាននាក់ត្រូវបានសម្លាប់ ហើយអ្នកដែលនៅរស់រានមានជីវិត នៅតែមានអារម្មណ៍ភ័យខ្លាចចំពោះអ្វីដែលបានកើតឡើង ហើយធ្វើឲ្យប៉ះពាល់ដល់ផ្លូវចិត្ត និងរាងកាយជាទម្ងន់ ដោយសារការខ្វះខាតខាងសុខភាព អំពើឃោរឃៅ និងសង្គ្រាម។ យុវវ័យដែលកើត

Documentation Center of Cambodia (constituted in 1995)
Searching for the Truth: Memory & Justice
ស្វែងរកការពិត ដើម្បីការចងចាំនិងយុត្តិធម៌
66 Preah Sihanouk Blvd. ♦ P.O.Box 1110 ♦ Phnom Penh ▫Cambodia
t (855-23) 211-875 ♦ dccam@online.com.kh ♦ www.dccam.org

ក្រោយឆ្នាំ១៩៧៩ មានចម្លល់ថា "តើព្រឹត្តិការណ៍នេះកើតឡើងរបៀបយ៉ាងដូចម្តេច"។ នៅពេលដែលសំណួរនេះមានការពិបាកក្នុងការផ្តល់ចម្លើយ ការបង្កើតឲ្យមានការអនុវត្តការបង្រៀនពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅក្នុងថ្នាក់រៀន គឺជាការចាំបាច់បំផុត។ កាបង្រៀនពីប្រវត្តិសាស្ត្រនេះ គឺមិនត្រឹមតែថែរក្សាការចងចាំពីអ្នកដែលឈឺចាប់និងស្លាប់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធានាថាព្រឹត្តិការណ៍និងលក្ខខណ្ឌនានាដែលបានកើតមានជាបន្តបន្ទាប់ក្នុងអតីតកាល និងការមកដល់នៃអំពើហឹង្សានិងឃោរឃៅ គឺមិនអាចវិលត្រឡប់វិញឡើយ។ កម្មវិធីសិក្សានេះ ធ្វើឡើងដោយផ្អែកលើគោលវិធីសិស្សមជ្ឈមណ្ឌល និងកំណត់ព្រំដែនត្រឹមសកម្មភាពជុំវិញការលើកទឹកចិត្តឲ្យមានការយល់យោគគ្នាជាលក្ខណៈប្រវត្តិសាស្ត្រ ការពិភាក្សាការត្រិះរិះពិចារណាឲ្យស៊ីជម្រៅ និងការឆ្លុះបញ្ចាំងខ្លួនឯង។ មានសកម្មភាពមួយចំនួនរបស់វគ្គបណ្តុះបណ្តាល ដែលទាក់ទងនឹងការសិក្សាស្រាវជ្រាវ ការសរសេរដែលប្រកបដោយការច្នៃប្រឌិត ការសម្ភាសន៍ជាមួយឪពុកម្តាយនិងសហគមន៍ និងការធ្វើបទបឋកថារបស់ភ្ញៀវ។ នៅពេលដែលមានការលំបាកក្នុងការបង្រៀនពីប្រវត្តិសាស្ត្រនេះ វាគឺជាការចាំបាច់ណាស់ សម្រាប់ការចាប់ផ្តើមអនាគតរបស់កម្ពុជានិងយុត្តិធម៌អន្តរកាលដ៏ធំសម្បើម។

វគ្គបណ្តុះបណ្តាលនេះ មានវត្ថុបំណងដូចតទៅ៖

១) អភិវឌ្ឍចំណេះដឹងរបស់គ្រូបង្រៀនពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ។

២) អភិវឌ្ឍជំនាញគរុកោសល្យរបស់គ្រូបង្រៀន ពីរបៀបបង្រៀនពីប្រវត្តិសាស្ត្រកម្ពុជាប្រជា ធិបតេយ្យ។

៣) អភិវឌ្ឍសមត្ថភាពរបស់គ្រូបង្រៀនឲ្យចេះប្រើប្រាស់បទពិសោធន៍របស់សាក្សីក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ សម្រាប់ប្រើប្រាស់ក្នុងការបង្រៀនក្នុងថ្នាក់រៀន។

៤) បង្កើនប្រសិទ្ធិភាព និងនិរន្តរភាពនៃកម្មវិធីសិក្សាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យជាផ្លូវការ ជាមួយក្រសួងអប់រំ យុវជន និងកីឡា នៅតាមសាលារៀនក្នុងសហគមន៍។

៥) បង្កើនប្រសិទ្ធិភាព និងនិរន្តរភាពនៃកម្មវិធីសិក្សាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យជាផ្លូវការ ជាមួយក្រសួងអប់រំ យុវជន និងកីឡា នៅកម្រិតសាកលវិទ្យាល័យ។

**វាគ្មិន៖**

**គ្រីស្តូហ្វ័រ ឌៀរីង** គឺនិយាយក្នុងនាមគាត់ជាទីប្រឹក្សាអប់រំឯករាជ្យ។ ក្នុងនាមជាទីប្រឹក្សាអប់រំឯករាជ្យ គាត់គឺជាសហអ្នកនិពន្ធជាមួយបណ្ឌិត ជា ផល្លា បានបោះពុម្ពសៀវភៅណែនាំគ្រូបង្រៀនសម្រាប់ប្រើប្រាស់ក្នុងវគ្គបណ្តុះបណ្តាលនេះ មានចំណងជើងថា "សៀវភៅណែនាំគ្រូបង្រៀន៖ ការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ" ក៏ដូចជាការបោះពុម្ពសៀវភៅមួយចំនួនទៀត រួមទាំងសៀវភៅ "ប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង៖ តំបន់កាន់កាប់ចុងក្រោយរបស់ចលនាខ្មែរក្រហម" (គាត់គឺជាសហអ្នកនិពន្ធជាមួយបណ្ឌិត ឌី ខាំបូលី)។

ឯកអគ្គរដ្ឋទូត **ចូលីយ៉ូ ដែលជ្រេស** គឺជាទីប្រឹក្សាខុទ្ទកាល័យព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងជាពិធីការរបស់រដ្ឋមន្ត្រីក្រសួងការបរទេស។ លោកក៏ជាសាស្ត្រាចារ្យប្រវត្តិសាស្ត្រនិងចិត្តវិទ្យា នៃសាកលវិទ្យាល័យម៉ូណាស់ និងជាអ្នកសរសេរពីជីវប្រវត្តិរបស់អតីតសម្តេចព្រះ នរោត្តម សីហនុ តាំងពីឆ្នាំ១៩៩៩មក។ សៀវភៅទាំងនោះរួមមាន៖ "ព្រះបរមរាជវាំងនៃរាជធានីភ្នំពេញ និងជីវិតក្សត្រនៅកម្ពុជា (បោះពុម្ពឆ្នាំ១៩៩៩)" "រាជវាំងនៅកម្ពុជា (បោះពុម្ពឆ្នាំ២០០៣)" "ស្រមោលលើអង្គរ៖ ព្រះរាជជីវប្រវត្តិរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ (បោះពុម្ពឆ្នាំ២០០៥)" និង "ជីវិតជាការឧទ្ទិសដល់កម្ពុជា៖ ពិធីប្រារព្ធខួបពីជីវិតនិងពេលវេលារបស់ព្រះករុណាព្រះបាទសម្តេចព្រះបិតាជាតិ ព្រះបាទសម្តេចព្រះ នរោត្តម សីហនុនៃកម្ពុជា (បោះពុម្ពឆ្នាំ២០០៥)"។

វគ្គបណ្តុះបណ្តាលនេះមិនអាចប្រព្រឹត្តិទៅបានឡើយ ប្រសិនបើគ្មានការជួយទ្រទ្រង់ពីម្ចាស់ជំនួយដូចខាងក្រោម៖

*សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖*

**ផេង ពង្សរ៉ាស៊ី**

អ្នកសម្របសម្រួល គម្រោងស្តីពីការអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា

ទូរស័ព្ទ៖ ០១២ ៦៩ ៦៩ ៦១

អ៊ីមែល៖ truthrasy.p@dccam.org